**សាររបស់លោកអភិបាល អូលីវីយេ**
**ផ្ញើទៅមេក្រុមកាយឫទ្ធិភូមិភាគភ្នំពេញ**
**ចំការទៀន ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០**

មេក្រុមកាយឫទ្ធិជាទីស្រឡាញ់!

សេចក្តីប្រកាសសម្រាប់មេក្រុមកាយឫទ្ធិ នៅក្នុងភូមិភាគភ្នំពេញទាំងអស់ តាមរយៈការិយាល័យយុវជន ជំទង់ និងកុមារភូមិភាគភ្នំពេញ។ នៅថ្ងៃសៅរ៍សប្តាហ៍ក្រោយ តាមកន្លែងនីមួយៗដែលយើងអាចជួបជុំគ្នាជាមួយមេក្រុមកាយឫទ្ធិមួយចំនួន (មិនមែនជាមួយកូនក្មេង) មានមួយក្រុង៥នាក់ ឬមួយក្រុម១០នាក់ ដើម្បីគិតគូរសំនួរថា "**យើងជាមេក្រុមកាយឫទ្ធិ តើយើងអាចបង្កើតសកម្មភាពអ្វីខ្លះ ដើម្បីបម្រើបងប្អូននៅក្នុងសង្គមដែលមានទុក្ខលំបាក?**" លោកតាម្នាក់ លោកយាយម្នាក់ អ្នកជំងឺម្នាក់ បងប្អូនដែលកំពុងពិបាកដោយសាររោងចក្របិទទ្វារ ក្មេងៗដែលទៅសាលាមិនបាន ឬអត់មានអ៊ីនធើណេតដើម្បីភ្ជាប់ជាមួយសកម្មភាពបង្រៀនពីចម្ងាយ (E-leaning) របស់ក្រសួងអប់រំ យុវជន និងកីឡា។ ដូច្នេះ ជាឱកាសមួយដើម្បីគិត ម្យ៉ាងទៀតខ្ញុំសូមឲ្យមេក្រុមកាយឫទ្ធិប្រមូលលុយផ្ទាល់ខ្លួនខ្លះៗ ម្នាក់មួយពាន់រៀល ពីរពាន់រៀល ឬមួយដុល្លារ ដើម្បីឲ្យមានស្នាដៃយ៉ាងជាក់ស្តែង។ ក្រោយមកនៅថ្ងៃអាទិត្យ យើងអនុវត្តជាក់ស្តែងអំពីធម៌មេត្តាករុណា តាមរយៈមេក្រុមកាយឫទ្ធិនៅក្នុងភូមិភាគភ្នំពេញ។

ដូច្នេះ ខ្ញុំសូមឲ្យមេក្រុមកាយឫទ្ធិជួបជុំគ្នាថ្ងៃសៅរ៍សប្តាហ៍ក្រោយ ពេលវេលាណាមួយតាមដែលអាចធ្វើបាន។ ព្រឹកឡើងថ្ងៃអាទិត្យ យើងអាចមានសកម្មភាពខ្លះៗ ដើម្បីបង្ហាញសេចក្តីស្រឡាញ់ដែលយើងមានដល់បងប្អូនទាំងនោះ។ សូមកុំទៅសុំលុយលោកឪពុក គឺសូមប្រមូលលុយយើងផ្ទាល់ខ្លួន យើងមានសមត្ថភាពដៃឬដើម្បីជួយសកម្មភាពមេត្តាករុណាអស់ពីដួងចិត្ត ដោយសារយើងជាអ្នកស្ម័គ្រស្លាប់សម្រាប់ព្រះយេស៊ូ និងសម្រាប់ព្រះសហគមន៍។